ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ: ...០២៨...សសរ../គ.ជ.អ.ប

# សេចក្ដីសម្រេច

## ស្ដីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការគ្រប់គ្រងការអនុវត្ត ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១១ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៥ និងមាត្រា១៧ និងបន្ថែមមាត្រា១២ស្ទួន នៃអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៦៥ ប្រក/គ.ជ.អ.ប ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានគ.ជ.អ.ប
- បានឃើញកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩

- បានឃើញផែនការអនុវត្តបីឆ្នាំដំណាក់កាលទីពីរ (២០១៥-២០១៧) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ផអ៣ទី២)ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤
- បានឃើញផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣
- លិខិតចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការរៀបចំគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ ដែលសរសេរជាអក្សរកាត់ថា"គ.គ.អ.ស" និងសរសេរជាអក្សរអង់គ្លេស "Implementation Social Accountability Framework Partnership Steering Committee (I-SAF PSC)"។

**ប្រការ ២.-**

"គ.គ.អ.ស" ត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីផ្តល់វេទិកាសម្រាប់កិច្ចពិភាក្សា និងធ្វើសេចក្តីសម្រេចចិត្តលើការរៀបចំគោលនយោបាយ ផែនការសកម្មភាពនិងថវិកា ការកំណត់តំបន់គោលដៅ និងនីតិវិធីគាំទ្រការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ។

**ប្រការ ៣.-**

ត្រូវបានតែងតាំងសមាសភាពរបស់គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១.ឯកឧត្តម **ទី ច័ន្ទផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាសមាជិកគ.ជ.អ.ប | ជាប្រធាន |
| ២.លោក **សឿង សារឿន** | នាយកប្រតិបត្តិគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា | ជាអនុប្រធាន |
| ៣.ឯកឧត្តម **លេង ទី** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៤.លោកជំទាវ **ឃុន រចនា** | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | ជាសមាជិក |
| ៥.ឯកឧត្តម **ខាម ម៉េរា** | អគ្គនាយករង និងជាប្រធានអង្គភាពត្រួតពិនិត្យវាយតម្លៃ និងព័ត៌មាន នៃលេខាធិការដ្ឋាន គ.ជ.អ.ប | ជាសមាជិក |
| ៦.លោកបណ្ឌិត **ទី សុខវណ្ណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧.លោក **ហុក ខៀវ** | ប្រធាននាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ ក្រសួងសុខាភិបាល | ជាសមាជិក |
| ៨.លោក **ម៉ូត សោភណា** | នាយកប្រតិបត្តិផ្នែកកម្មវិធី អង្គការសង្គ្រោះកុមារ | ជាសមាជិក |
| ៩.លោក **ឈ ចន្ទសុផល** | ប្រធានផ្នែកអភិបាលកិច្ច និងវិមជ្ឈការ អង្គការជេកកម្ពុជា | |

ហ៊

១០.លោកវេជ្ជបណ្ឌិត **តុលា ឈារ៉ាឆុង** នាយកកសាងសម្ថភាពអង្គការសម្ព័ន្ធ ជាសមាជិក

សុខភាពកុមារ និងសុខភាពបន្តពូជ ជាសមាជិក

១១.លោក **គេខ ម៉ិនឈឿត** តំណាងក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ

១២.លោក **ឡេង ទីរៈ** នាយករងប្រតិបត្តិការ អង្គការទស្សនៈពិភពលោក ជាសមាជិក

១៣.តំណាងដៃគូអភិវឌ្ឍន៍ ០២រូប អ្នកអង្កេតការណ៍

**ប្រការ ៤.-**

"គ.គ.អ.ស" ត្រូវជួបប្រជុំយ៉ាងតិចបួនដងក្នុងមួយឆ្នាំ រាល់ការធ្វើសេចក្តីសម្រេចចិត្ត នឹងត្រូវធ្វើឡើងដោយមានការព្រមព្រៀងគ្នាដោយមានសម្លេងគាំទ្រភាគច្រើនដាច់ខាត ក្នុងពេលអនុម័តប្រសិនបើមានសម្លេងគាំទ្រស្មើគ្នា សម្លេងប្រធានអង្គប្រជុំមានឧត្តមានុភាព។ "គ.គ.អ.ស" អាចរៀបចំកិច្ចប្រជុំវិសាមញ្ញបាន តាមការចាំបាច់ និងដោយមានការកោះអញ្ជើញពីប្រធាន "គ.គ.អ.ស"។

តួនាទី និងការទទួលខុសត្រូវរបស់"គ.គ.អ.ស" រួមមាន៖

- ធានាឱ្យមានការអនុវត្តទាំងផ្នែកផ្គត់ផ្គង់(តួអង្គរដ្ឋ) និងផ្នែកតម្រូវការ (ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល) តាមគោលការណ៍នានា នៃផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម និងផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- ផ្តល់ជាវេទិកាសម្រាប់កិច្ចសហការតាមរយៈការពិភាក្សា និងផ្តល់យោបល់ត្រឡប់រវាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។
- ធ្វើការសម្រេចចិត្ត និងកៀរគរថវិកា សម្រាប់គាំទ្រអនុវត្តផែនការបីឆ្នាំ និងកិច្ចព្រមព្រៀងនានា។
- ពិនិត្យឡើងវិញ និងផ្តល់អនុលោមភាព ទៅលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ទាក់ទងទៅនឹងការងារគណនេយ្យភាពសង្គម និងទទួលរបាយការណ៍អំពីវឌ្ឍនភាព និងរបាយការណ៍វាយតម្លៃការអនុវត្ត ដោយផ្តោតទៅលើមេរៀនបទពិសោធន៍នានា។
- ធ្វើការសម្រេចចិត្ត និងកិច្ចព្រមព្រៀង ក្នុងការកំណត់ស្រុកគោលដៅ (គ្រប់ឃុំ គ្រប់មណ្ឌលសុខភាព និងគ្រប់សាលាបឋមសិក្សា) សម្រាប់អនុវត្តការងារគណនេយ្យភាពសង្គម នឹងត្រូវធ្វើឡើងតាមរយៈអនុស្សារណៈយោគយល់ ដោយធានាឲ្យមានផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តរវាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។
- ឯកសារគោលនយោបាយដែលពាក់ព័ន្ធជាមួយផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម នីតិវិធីអនុវត្ត និងឯកសារបច្ចេកទេស អាចកែសម្រួលទៅបាន អាស្រ័យលើការពិគ្រោះយោបល់និងផ្តល់យោបល់ត្រឡប់ប្រចាំឆ្នាំ។
- ផ្តល់វេទិកាសម្រាប់ពិគ្រោះយោបល់ និងដំណោះស្រាយសមស្របចំពោះបញ្ហាដែលបានកើតឡើងនៅក្នុងពេលអនុវត្ត និងសម្របសម្រួលរវាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។
- ទទួល និងដោះស្រាយបណ្តឹងតវ៉ា ពីផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ នៅពេលដែលមិនបានអនុវត្តស្របទៅតាមគោលការណ៍នៃភាពជាដៃគូ និងការរៀបចំអនុវត្តនានានៃការងារគណនេយ្យភាពសង្គម។

- ពិនិត្យ និងផ្តល់អនុលោមភាពទៅលើផែនការអភិវឌ្ឍសមត្ថភាព និងការពិនិត្យមើលឡើងវិញទៅលើការអនុវត្តការងារគណនេយ្យភាពសង្គមរបស់ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។
- ពិភាក្សាអំពីបញ្ហាផ្សេងទៀត ទៅតាមការសម្រេចរបស់ប្រធាន គ.គ.អ.ស ។

**ប្រការ ៥.-**

ប្រធាន និងអនុប្រធាននៃ "គ.គ.អ.ស" មានតួនាទី និងភារកិច្ចក្នុងការសម្របសម្រួល ដឹកនាំកិច្ចប្រជុំ ដើម្បីធានាថាការងារគណនេយ្យភាពសង្គម ត្រូវបានអនុវត្តដោយប្រសិទ្ធភាព និងប្រសិទ្ធផល រវាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។

**ប្រការ ៦.-**

តួនាទី និងភារកិច្ចនៃ "គ.គ.អ.ស" អាចធ្វើវិសោធនកម្មទៅតាមការចាំបាច់បាន លុះត្រាតែមានការយល់ព្រមពីសមាជិកនានានៃគណៈកម្មាធិការនេះ។

**ប្រការ ៧.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨.-**

សមាជិកគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលពាក់ព័ន្ធ លេខាធិការដ្ឋាន គ.ជ.អ.ប និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ៣ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ឧ.៣ ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល
-ក្រសួងអប់រំ យុវជន និងកីឡា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អង្គការទស្សនៈពិភពលោក អង្គការសង្គ្រោះកុមារ
-អង្គការសម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ
-អង្គការក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ និង
-អង្គការផ្តេកកម្ពុជា
" ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ